**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ការិយាល័យអ្នកនាំពាក្យ**

**លេខ ៣២៤ សប្រក**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង :

**១-សេចក្តីព្រាងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ**

**២-បញ្ហាផ្សេងៗ**

ក្រោយពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេចឯកភាព :

### I-លើសេចក្តីព្រាងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ

សេចក្តីព្រាងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិនេះ ត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថានក្រោមការជួយឧបត្ថម្ភគាំទ្រផ្នែកថវិកា និងបច្ចេកទេសរបស់អង្គការ **IUCN** ធនាគារពិភពលោក **(WB)** និងមូលនិធិបរិស្ថានពិភពលោក **(GEF)** ក្នុងគោលបំណងធានានូវការគ្រប់គ្រងការអភិរក្សជីវៈចំរុះ និងធានាការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

តំបន់ការពារធម្មជាតិត្រូវបានចែកចេញជា ៤ តំបន់គ្រប់គ្រងរួមមាន :

១-**តំបន់ស្នូល** : ជាតំបន់គ្រប់គ្រង ដែលមានតំលៃខ្ពស់សំរាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់គំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។

២-**តំបន់អភិរក្ស** : ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតំលៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធ អេកូឡូស៊ី តំបន់ទីជំរាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ ។

៣-**តំបន់ប្រើប្រាស់ដោយចីរភាព** : ជាតំបន់គ្រប់គ្រង ដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ បំរើដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកំពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៤-**តំបន់សហគមន៍** : ជាតំបន់គ្រប់គ្រងបំរើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែចំការ ។

សេចក្តីព្រាងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិមាន ១១ ជំពូក និង ៦៦ មាត្រា ។

## II-អំពីបញ្ហាផ្សេងៗ

គណៈរដ្ឋមន្ត្រីបានឯកភាពបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិដើម្បីសុំ សច្ចាប័ននូវ :

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមបាគីស្ថាន ស្តីពីការជំរុញ និងការការពារវិនិយោគ

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអូទ្រីស ស្តីពីការ ជំរុញ និងការការពារវិនិយោគ ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១២ និង ១៥ នាទី ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ២០០៥